# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាសំណាក់ធម៌នៅអរិយក្សត្រ
# ថ្ងៃទី២៥ មីនា ២០១៧

អត្ថបទទី១៖ អស ៧,១០-១៤;៨,១០
អត្ថបទទី២៖ ហប ១០,៤-១០
ដំណឹងល្អ៖ លក ១,២៦-៣៨

បងប្អូនជាទីស្រឡាញ់!

យើងបានស្តាប់នៅក្នុងអត្ថបទទីមួយ **"ព្រះអម្ចាស់ចាត់លោកអេសាយឲ្យទៅទូលព្រះបាទអខាសសាជាថ្មីថា (ព្រះករុណាត្រូវទូលសុំព្រះអម្ចាស់ ជាព្រះរបស់ព្រះករុណាសំដែងនូវទីសម្គាល់មួយ ទោះបីនៅលើភ្នំដ៏ខ្ពស់ក្តី ឬក្នុងទឹកដ៏ជ្រៅក្តី ដើម្បីបញ្ជាក់ថាព្រះអង្គពិតជាគង់នៅជាមួយព្រះករុណា)"**។ នេះជាអ្វីដែលយើងបានសុំព្រះជាម្ចាស់ជាច្រើនដងច្រើនសារ ឲ្យព្រះជាម្ចាស់ប្រទានសញ្ញាសម្គាល់មួយដើម្បីឲ្យយើងជឿលើព្រះអង្គ ដើម្បីឲ្យយើងសុខចិត្តដើរតាមព្រះជាម្ចាស់ ដើម្បីឲ្យជីវិតរបស់ខ្ញុំទៅមុខ ដើម្បីឲ្យជំនឿរបស់រីកចម្រើនថែមទៀត។ ក្រោយមកព្រះជាម្ចាស់បានឆ្លើយតបព្រះមហាក្សត្រថា នឹងមានកូនក្មេងម្នាក់ ហើយថ្វាយព្រះនាមថាអេម៉ាណូអែល (ត្បិតព្រះជាម្ចាស់គង់នៅជាមួយយើង) ប៉ុន្មានឆ្នាំក្រោយមកកូននេះបានកើតគឺព្រះយេស៊ូតែម្តង។

នៅក្នុងជីវិតរបស់យើង យើងចង់ឃើញសញ្ញាយ៉ាងច្រើន ជួនកាលយើងសង្ឃឹមបានទទួលសញ្ញាអស្ចារ្យមួយ។ ប៉ុន្តែតាមពិតពេលព្រះនាងម៉ារី បានទទួលដំណឹងពីទេវទូតអត់មានអ្វីពិសេសដើម្បីឲ្យព្រះនាងម៉ារីឃើញ គឺព្រះនាងម៉ារីគ្រាន់តែលឺដំណឹងមួយប្លែកធ្វើជាមាតារបស់ព្រះជាម្ចាស់។ ខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ។ សញ្ញាសម្គាល់ដែលព្រះនាងម៉ារីបានទទួល គាត់លឺសម្លេងមួយដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅព្រះនាងម៉ារី ប៉ុន្តែព្រះនាងម៉ារីទៅជាសញ្ញាមួយពិសេសសម្រាប់ពិភពលោក ដោយសារព្រះនាងម៉ារីបានធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ព្រះនាងម៉ារីបានទទួលដំណឹងពីទេវទូតកាព្រីអែល ឲ្យធ្វើជាមាតារបស់ព្រះជាម្ចាស់ ទោះបីគាត់មិនសូវយល់ ប៉ុន្តែគាត់បានឯកភាព ហើយព្រះនាងម៉ារីទៅជាសញ្ញាសម្គាល់មួយយ៉ាងអស្ចារ្យសម្រាប់មនុស្សលោក។

សព្វថ្ងៃយើងបន្តទន្ទឹងរងចាំសញ្ញាយ៉ាងច្រើន ប៉ុន្តែជួនកាលយើងមិនចេះបើកភ្នែកសោះ បើយើងចេះបើកភ្នែកយើងឃើញសញ្ញាយ៉ាងច្រើនដែលណែនាំឲ្យយើងយល់ថាពិត

មែនព្រះជាម្ចាស់ថែរក្សាយើង។ ដូចនៅអរីយក្សត្រនេះ ជាកន្លែងពិសេសចាប់ពីយើងបាន រកឃើញព្រះនាងម៉ារីទីមួយនៅក្នុងទន្លេមេគង្គនៅឆ្នាំ២០០៨ ទីពីរនៅឆ្នាំ២០១២។ ព្រះនាង ម៉ារីទីមួយ គឺអ្នកនេសាទត្រីជនជាតិអ៊ីស្លាមជាអ្នកស្រង់ព្រះនាងចេញពីទន្លេ ព្រះនាងម៉ារីទី ពីរ គឺជាពុទ្ធបរិស័ទម្នាក់ដែលសព្វថ្ងៃគាត់ជាកាតូលិក គាត់បានស្តាប់សម្លេងព្រះនាងម៉ារី បីដងសុំទៅមើលៗ គាត់បានទៅកន្លែងនោះបានឃើញព្រះនាងម៉ារីតែម្តង។ ដូច្នេះកន្លែង នេះទៅជាកន្លែងដ៏វិសុទ្ធ ដើម្បីឲ្យគ្រីស្តបរិស័ទចេញចូលទទួលព្រះពរពីព្រះជាម្ចាស់ ដោយ សារយើងបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយយើងធ្វើតាម។ នេះជាសញ្ញាមួយ សម្រាប់ជីវិតរបស់យើង ដូច្នេះកុំឲ្យយើងគិតវែងឆ្ងាយ ថ្ងៃនេះយើងមានបងប្អូនមួយចំនួន បានមក ដើម្បីអធិដ្ឋាន សូត្រធ្ម៌ ចូលអភិបូជាដើម្បីអរព្រះគុណព្រះជាម្ចាស់ដែលបាន ប្រទានព្រះនាងម៉ារីឲ្យព្រះសហគមន៍កម្ពុជា ដែលបានប្រទានព្រះយេស៊ូដើម្បីឲ្យយើងមាន ជីវិតថ្មី នេះជាសញ្ញាមួយសម្រាប់ជីវិតរបស់យើង។ កម្មវិធីដែលយើងមានថ្ងៃនេះ គឺរាល់ខែ ក្នុងអាទិត្យទីបួនមានបូជាចារ្យម្នាក់ដែលមកណែនាំអប់រំ ថ្វាយអភិបូជា ដើម្បីឲ្យយើងទាំង អស់បានទទួលព្រះពរថែមទៀត ដើម្បីទៅជាសញ្ញាសម្គាល់នៃជីវិតដែលយើងបានទទួល ព្រះជាម្ចាស់។ ដូចពីសម័យដើម មនុស្សលោកកំពុងទន្ទឹងសញ្ញាមួយយ៉ាងពិសេសដើម្បី មានជំនឿលើព្រះជាម្ចាស់ តាមពិតសញ្ញាពិសេសមិនមែនអ្វីអស្ចារ្យប៉ុន្មានទេ ដូចយើងស្តា ប់ថ្ងៃនេះគឺព្រះនាងម៉ារីបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងអនុវត្តតាមព្រះបន្ទូល នោះ ដើម្បីណែនាំឲ្យព្រះយេស៊ូប្រសូតនៅក្នុងពិភពលោក និងណែនាំឲ្យយើងទាំងអស់ មានជីវិតនេះជាសញ្ញាដែលយើងធ្វើតាមសញ្ញានេះ។

ថ្ងៃនេះខ្ញុំចង់ឲ្យបងប្អូនគិតពិចារណា ដើម្បីឆ្លើយតបដល់សេចក្តីសង្ឃឹមរបស់មនុស្ស លោកដែលកំពុងទន្ទឹងរង់ចាំសញ្ញាអ្វីមួយ ដើម្បីឲ្យជីវិតរបស់គេមានសុភមង្គល អាចមាន សេចក្តីសង្ឃឹមថែមទៀត យើងត្រូវការយល់ថាយើងម្នាក់ៗរៀងៗខ្លួនអាចទៅជាសញ្ញានេះ សម្រាប់បងប្អូនឯទៀតៗ។ មានន័យថា យើងអាចធ្វើជាសញ្ញាមួយពិសេសសម្រាប់អ្នកដទៃ យើងអាចធ្វើបានលុះត្រាតែ ទីមួយយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារី ទីពីរយើងស្វាគមន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារី ទីបីយើងសុខចិត្តអនុវត្ត ដោយរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារីដែរ។ ប៉ុន្តែដើម្បីស្តាប់ព្រះ បន្ទូល ដើម្បីស្វាគមន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារី យើងត្រូវការរៀបចំចិត្ត

គំនិតរបស់យើង។ កុំគិតថាពេលព្រះនាងម៉ារីបានទទួលដំណឹងពីទេវទូតកាព្រីអែល ព្រះនាងម៉ារីមិនដែលរៀបចំខ្លួន តាំងពីឪពុកម្ដាយរបស់ព្រះនាងម៉ារីបានថ្វាយព្រះនាងម៉ារីនៅក្នុងព្រះវិហារយេរូសាឡឹម ពីពេលនោះព្រះនាងម៉ារីបានរៀបចំខ្លួនជានិច្ច។ គាត់រៀបចំខ្លួនដោយដឹងថាអនាគតគាត់ក្លាយជាម្ដាយរបស់ព្រះជាម្ចាស់ ប៉ុន្តែនៅក្នុងជីវិតធម្មតារបស់គាត់ គាត់បានអធិដ្ឋាន គាត់ភ្ជាប់ជាមួយព្រះជាម្ចាស់។ ដូច្នេះនៅថ្ងៃដែលទេវទូតកាព្រីអែលមកប្រាប់ដំណឹងដល់ព្រះនាងម៉ារី គាត់ទទួលយកបានដោយសារគាត់បានរៀបចំចិត្តគំនិតហើយ។

សម្រាប់យើងក្នុងរដូវ៤០ថ្ងៃនេះ ជាឱកាសមួយដើម្បីរៀបចំចិត្តគំនិត។ សម្តេចប៉ាបបានសរសេរសារលិខិតឲ្យគ្រីស្តបរិស័ទទូទាំងពិភពលោកថា **"ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះអំណោយទានរបស់ព្រះជាម្ចាស់សម្រាប់ជីវិតយើង ប៉ុន្តែព្រះបន្ទូលរបស់ព្រះជាម្ចាស់យើងត្រូវការស្តាប់ជានិច្ចដោយរៀបចំចិត្តគំនិតរបស់យើង"** នៅពេលយើងបានស្តាប់ហើយយើងអាចស្វាគមន៍បាន ប៉ុន្តែប្រសិនបើចិត្តគំនិតរបស់យើង ដូចចិត្តគំនិតរបស់អ្នកមាននៅក្នុងគម្ពីរដែលមិនចេះមើលលោកឡាសាជាអ្នកក្រីក្រនៅក្បែរទ្វារផ្ទះរបស់គាត់ ប្រសិនបើចិត្តគំនិតរបស់យើងចង្អៀតចង្អល់អស់ហើយ ទោះយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់អ្វីក៏បាន ក៏គ្មានឥទ្ធិពលនៅក្នុងជីវិតរបស់យើងដែរ។

ថ្ងៃនេះយើងទូលអង្វរព្រះជាម្ចាស់ ដើម្បីឲ្យយើងបន្តរៀបចំចិត្តគំនិតដោយយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ស្វាគមន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតយើង និងឆ្លើយតប ដូចព្រះនាងម៉ារីដែលបានឆ្លើយតែមួយម៉ាត់ដែលណែនាំឲ្យពិភពលោកទៅជាពិភពថ្មី។ ពេលព្រះនាងម៉ារីនិយាយថា **"នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ"** មួយម៉ាត់នេះ ណែនាំឲ្យព្រះសង្គ្រោះប្រសូតជាមនុស្សបាន។ យើងត្រូវយល់ថា មនុស្សលោកសព្វថ្ងៃទន្ទឹងរងចាំសញ្ញាសម្គាល់ថែមទៀត មិនទន្ទឹងរងចាំតែមានអាគារខ្ពស់ៗអស្ចារ្យ ប៉ុន្តែមនុស្សលោកទន្ទឹងរងចាំសញ្ញាសម្គាល់ដែលណែនាំឲ្យមានសេចក្តីសង្ឃឹម។ យើងទាំងអស់គ្នាទៅជាសញ្ញាសម្គាល់នេះបាននៅពេលយើងស្តាប់ព្រះបន្ទូល ស្វាគមន៍ហើយយើងអនុវត្តដោយបម្រើបងប្អូនឯទៀតៗ ដោយណែនាំឲ្យអ្នកដទៃមានសេចក្តីសង្ឃឹមថែមទៀត ណែនាំឲ្យមនុស្សដែលរងទុក្ខលំបាករកឃើញពន្លឺ ដោយណែនាំឲ្យកូនក្មេងអនាថា គ្មេងដែលមិនបានចូលទទួលការអប់រំ

ខ្វះម្ហូបអាហារ ខ្វះអនាម័យ ពិការ យើងធ្វើយ៉ាងណាដើម្បីជួយគេខ្លះឲ្យពិភពលោករបស់យើងទៅជាពិភពថ្មី។ យើងអាចធ្វើបានលុះត្រាតែយើងស្តាប់ព្រះបន្ទូល យើងស្វាគមន៍ព្រះបន្ទូលនេះ និងយើងអនុវត្តព្រះបន្ទូលនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គជួយយើង ដើម្បីឲ្យយើងដូចព្រះនាងម៉ារី ដោយឲ្យយើងទៅជាសញ្ញាសម្គាល់របស់ព្រះជាម្ចាស់ សម្រាប់មនុស្សលោកទាំងឡាយ។ មិនមែនសញ្ញាសម្គាល់អស្ចារ្យ ប៉ុន្តែជាសញ្ញាសម្គាល់ដែលស្ងៀមស្ងាត់ ដែលណែនាំឲ្យជីវិតរបស់មនុស្សម្នាក់អាចទទួលជីវិតថ្មី។ ដូច្នេះនៅក្នុងរដូវ៤០ថ្ងៃនេះ ឲ្យយើងសម្រេចចិត្តតើយើងធ្វើអ្វីខ្លះដើម្បីជួយមនុស្សតែម្នាក់បានទទួលជីវិតថ្មី ជួយតែម្នាក់ឲ្យគាត់រកឃើញសេចក្តីសង្ឃឹមនៅក្នុងជីវិត ជួយតែម្នាក់ឲ្យគាត់មានអំណរសប្បាយនៅក្នុងជីវិត។ ឲ្យយើងចេះមើលឃើញឡាសាជានិច្ចដូចព្រះនាងម៉ារី និយាយតែមួយម៉ាត់ដែលណែនាំឲ្យការសង្គ្រោះយាងមកនៅក្នុងពិភពលោកយើង។ អាម៉ែន។